# ចម្លាក់អ្នករាំ និងតន្ត្រីករនៅស.វ.ទី៧

យ៉ាងហោចណាស់ គេឃើញមានផ្តែរចំនួន ៣ ផ្ទាំងនៅស.វ.ទី៧ ដែលមានចម្លាក់បង្ហាញអំពីអ្នករាំ និងអ្នកប្រគំភ្លេងជាច្រើននាក់តម្រៀបគ្នាជាជួរ រួមមាន៖ ផ្តែរទ្វារខាងលិចនៃប្រាសាទយាយព័ន្ធ (S1) (រូបលេខ១) ផ្តែរទ្វារមកពីថាឡាបរិវ៉ាត់ (រូបលេខ២) និងផ្តែរទ្វារវត្តមហារ (រូបលេខ៣)។ ចម្លាក់បង្ហាញអ្នករាំ និងតន្ត្រីករទាំងនេះ ប្រាកដជាសិល្បករចង់បង្ហាញអំពីអត្ថន័យអ្វីមួយជាក់ជាមិនខាន។ នៅក្នុងឆ្នាំ២០២២ លោកស្រី **Swati Chemburkur** បានទាញសេចក្តីសន្និដ្ឋានថា អ្នករាំ និងអ្នកប្រគំភ្លេងទាំងនេះ ទំនងជាអ្នកបួសនៅក្នុងព្រហ្មញ្ញសាសនា លទ្ធិព្រះឥសូរ ក្នុងនិកាយមួយដែលគេស្គាល់ឈ្មោះថា "**បាសុបត**" ហើយអ្នកបួសទាំងនេះគឺជាអ្នកចាត់ចែងកិច្ចពិធីសាសនាបែបសិវនៅក្នុងរាជការខ្មែរនាសម័យនោះ។ តើអ្វីទៅជានិកាយបាសុបត? តើហេតុផលដែលលោកស្រី Swati Chemburkur សន្និដ្ឋានខាងលើនេះអាចសមហេតុផលត្រឹមកម្រិតណា?

បាសុបត គឺជានិកាយដ៏ចំណាស់មួយក្នុងចំណោមនិកាយចំនួន ៤ នៅក្នុងប្រព័ន្ធសិវនិយមនៃលទ្ធិព្រហ្មញ្ញសាសនា ដែលកើតឡើងនៅស្រុកឥណ្ឌារវាងស.វ.ទី២នៃគ្រឹស្តសករាជ។ ប្រព័ន្ធទស្សនវិជ្ជានៃនិកាយបាសុបតមានចំនួន ៥ យ៉ាង ហៅថា បញ្ចាថ៌-វិទ្យា (Pañcārtha-Vidyā) រួមមាន កាយ៌ (ផល ឬឥទ្ធិពល), ករន (ហេតុ), យោគ, វិធិ និងទុខាន្ត។ យោងទៅលើគម្ពីរ **បាសុបតសូត្រ** (Pāśupatasūtra) បានរៀបរាប់ថា អ្នកបួសនៅក្នុងនិកាយនេះ ត្រូវតែសំអាតខ្លួនជាមួយផេះក្នុងមួយថ្ងៃបីដង ត្រូវដេកជាមួយផេះ ត្រូវផ្ងូតទឹកបន្ថែមដោយផេះ ត្រូវស្លៀកសម្លៀកបំពាក់តែមួយ (ស្លៀកសំពត់) បួងសក់ឡើងលើ និងសៀតផ្កាដែលគេថ្វាយដល់ទេព។ អត្ថបទនេះក៏រៀបរាប់បន្ថែមថា ពួកគេត្រូវស្នាក់នៅក្នុងប្រាសាទដែលជាកន្លែងដ៏ពិសិដ្ឋរបស់ព្រះមហេសូរ ហើយនៅបម្រើព្រះតាមរយៈការផ្តល់ជូនសំណើច ការច្រៀង ការរាំ ការបង្កើតសំឡេងផ្សេងៗ ការស្ញឹងស្ញាតធម៌ក្នុងចិត្ត និងការសូត្រមន្ត្រ (mantra)។ ចំណែកនៅក្នុងអត្ថបទ **គណការិកា** (Gaṇakārikā) វិញ បានរៀបរាប់ថា ព្រាហ្មណ៍ បាសុបត ត្រូវដើរចូលទៅក្នុងបរិវេណប្រាសាទបន្ទាប់ពីផ្ងូតទឹកជាមួយផេះរួចរាល់ បន្ទាប់មកត្រូវសូត្រធម៌ ហើយក្រាបថ្វាយបង្គំដល់ព្រះសិវ។ បន្ទាប់មកទៀត ពួកគេត្រូវដើរចូលទៅក្នុងប្រាសាទ ដោយលត់ជង្គង់ខាងស្តាំរូបសំណាកព្រះសិវ ដោយត្រូវសើចឱ្យខ្លាំង ច្រៀង រាំ បង្កើតសំឡេង ហុឌុក្ការ (huḍukkāra) ដែលមានលក្ខណៈដូចនឹងសំឡេងសត្វគោ ដោយប្រើប្រាស់ចុងអណ្តាតជាមួយក្រអូមមាត់។ លើសពីនេះ ពួកគេត្រូវដើរប្រទក្សិណជុំវិញព្រះអាទិទេពចំនួនបីជុំ ហើយត្រូវគោរពព្រះដោយផ្តោតអារម្មណ៍តែម្យ៉ាងគត់ទៅលើព្យាង្គដែលត្រូវសូត្រ។ អ្វីដែលគួរកត់សម្គាល់នោះគឺ ពួកគេត្រូវរស់នៅជាធម្មតាជាមួយមនុស្ស និងត្រូវសំដែងអាកប្បកិរិយាអាក្រក់ និង

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

កាយវិការមិនសមរម្យផ្សេងៗ ដូចជាការធ្វើពុតជាដេកលក់ ការធ្វើពុតជាមនុស្សខ្វិនឬពិការ ការផឹកស្រាច្រើន ឬការក្លែងបន្លំខ្លួនជាមនុស្សស្រីជាដើម។

យោងតាមសិលាចារឹកសំខាន់ៗចំនួន ២ ផ្ទាំងនៅស.វ.ទី៧ ពោល គឺសិលាចារឹកប្រាសាទយាយព័ន្ធ (សំបូរព្រៃគុក) K.604 និងសិលាចារឹកភ្នំព្រះវិហារ (ខេត្តកំពង់ធ្នាំង) K.733 បានបង្ហាញភស្តុតាងមួយដ៏ជឿជាក់ថា នៅក្នុងរាជការខ្មែរនាស.វ.ទី៧ គឺមានពួកអ្នកបួស ឬពួកព្រាហ្មណ៍បាសុបតនៅបម្រើការឱ្យព្រះមហាក្សត្រខ្មែរពិតប្រាកដមែន ជាពិសេស គឺក្នុងរជ្ជកាលព្រះបាទភវវរ្ម័នទី១ (គ.ស.៦១៦-៦៣៧) និងព្រះបាទភវវរ្ម័នទី២ (គ.ស.៦៣៧-៦៥៧)។ តាមរយៈការសិក្សារបស់លោក **Wolters** យល់ឃើញថា ពួកព្រាហ្មណ៍ទាំងនេះជាមនុស្សមានចំណេះដឹងខ្ពង់ខ្ពស់ ទទួលបានការសព្វព្រះទ័យពីព្រះមហាក្សត្រខ្មែរ ហើយជានិច្ចកាលព្រះរាជាតែងតែបញ្ជាឱ្យពួកគេមើលថែសំណង់សាសនានៅក្នុងរាជធានី ព្រមទាំងស្តេចបានប្រទានអំណោយជាដីធ្លីដល់ពួកគេកាន់កាប់ថែមទៀតផង។ ការសន្និដ្ឋានរបស់លោកស្រី **Swati Chemburkur** ដូចរៀបរាប់ខាងលើ គឺលោកស្រីពិចារណាទៅលើចម្លាក់នៅផ្តែរទ្វាររូបលេខ៣ ដែលរកឃើញនៅវត្តមហរ (បារាំងហៅវត្តអង្គខ្នារ, សព្វថ្ងៃរក្សាទុកនៅសារមន្ទីរជាតិកម្ពុជា) ដែលបានបង្ហាញអំពីតួអង្គព្រាហ្មណ៍ជាច្រើននាក់ (ជិត ៣០ នាក់) កំពុងស្ថិតនៅក្នុងពិធីសាសនាអ្វីមួយ។ លោកស្រីយល់ថា តួអង្គកណ្តាលនៃចម្លាក់ដែលកំពុងអង្គុយនៅលើជើងទម្រ គឺជាព្រះរាជាខ្មែរនាស.វ.ទី៧ ហើយព្រាហ្មណ៍ទាំងអស់ដែលកំពុងធ្វើពិធីស្រង់ទឹក ឬពិធីអភិសេក គឺជាអ្នកបួសនៃនិកាយបាសុបត។ ការយល់ដូច្នេះ ក៏ដោយសារតែរូបចម្លាក់ទាំងនោះបង្ហាញអំពីតួអង្គទាំងអស់ស្លៀកពាក់ជាសម្លៀកអ្នកបួស (សម្លៀកបំពាក់ព្រាហ្មណ៍) និងមានបួងសក់ឡើងទៅលើ។ ជាពិសេសនោះ គឺតួអង្គទាំងនោះមានទាំងអ្នកប្រគុំឧបករណ៍តន្ត្រី និងមានទាំងអ្នករាំ ដែលលោកស្រីគិតថាវាមានភាពស៊ីគ្នាជាមួយនឹងការប្រណិប័តន៍ប្រចាំថ្ងៃរបស់ព្រាហ្មណ៍នៃនិកាយបាសុបត ដ្បិតដូចរៀបរាប់ខាងលើមកហើយថា អ្នកបួសនៃនិកាយនេះ ចូលចិត្តរាំ ច្រៀង ប្រគុំតន្ត្រី និងសើច។

ទោះបីជាយ៉ាងណា យើងពុំមានភស្តុតាងណាមកបញ្ជាក់ឱ្យច្បាស់ថា រូបតស្សរជនដែលនៅចំកណ្តាលផ្តែរទ្វារវត្តមហរ (វត្តអង្គខ្នារ) ពិតជាព្រះរាជានោះឡើយ។ ចំពោះ រូបតស្សរជននេះ ខ្ញុំធ្លាប់បានទាញសេចក្តីសន្និដ្ឋាននៅក្នុងអត្ថបទមុនម្តងរួចមកហើយថា ខ្ញុំគិតថារូបតស្សរជននៅចំកណ្តាលផ្តែរនោះគឺជាព្រះសិវក្នុងទម្រង់ជា "កបាលិន" ដែលជារូបភាពមួយរបស់ព្រះសិវនៅពេលតែងខ្លួនជាព្រាហ្មណ៍វ័យក្មេង ហើយដើរសុំទាននៅក្នុងព្រៃស្រល់ នៅក្នុងពេលធ្វើដំណើរទៅកាន់នគរពារាណសី ដើម្បីស្រង់ទឹកទន្លេគង្គាលាងជម្រះបាបកម្មនៅពេលដែលទ្រង់បានកាត់

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

ព្រះសិរមួយរបស់ព្រះព្រហ្ម។ នៅក្នុងករណីនេះ យើងគិតថា ការអះអាងរបស់លោកស្រី **Swati Chemburkur** ដែលយល់ថាអ្នករាំ និងតន្ត្រីករដែលបង្ហាញនៅលើផ្តែរទ្វារវត្តមហារ គឺជាព្រាហ្មណ៍បាសុបត គឺអាចទៅរួច ប៉ុន្តែខ្ញុំគិតថាពួកគេជាព្រាហ្មណ៍បាសុបតដែលកំពុងបង្ហាញនៅក្នុងរឿងទេវកថា (រឿងការបង្កើតលោកទាំងបី ឬរឿងសសរភ្លើង) ហើយពុំទំនងជាព្រាហ្មណ៍បាសុបតនៅក្នុងជួររាជការខ្មែរនោះឡើយ បើទោះបីកស្តុតាងសិលាចារឹកបានអះអាងថាព្រាហ្មណ៍និកាយនេះពិតជាបានមកបម្រើការងារនៅក្នុងរាជការខ្មែរពិតប្រាកដក៏ដោយ។

ជារួមមក ចម្លាក់អ្នករាំ និងអ្នកភ្លេងដែលបានបង្ហាញនៅលើផ្តែរទ្វារនាស.វ.ទី៧ ទាំងបីផ្ទាំងដូចជម្រាបជូនខាងលើ ទំនងជារូបភាពក្នុងរឿងទេវកថាណាមួយ ដែលបង្ហាញអំពីពួកព្រាហ្មណ៍និកាយបាសុបតកំពុងរាំច្រៀងសប្បាយតាមបែបប្រពៃណីរបស់ពួកអ្នកបួសនិកាយនេះ ដូចមានចែងនៅក្នុងគម្ពីរបាសុបតសូត្រ និងគម្ពីរគណការិកា ដោយយោងទៅលើការបួងសក់ និងរបៀបនៃការស្លៀកពាក់ និងការសំដែងអាកប្បកិរិយារបស់ពួកគេ។ យ៉ាងណាក៏ដោយការសន្និដ្ឋាននេះនៅមានចំណុចខ្វះខាតជាច្រើនទៀត ដែលត្រូវសិក្សាស្រាវជ្រាវបន្តទៀតនៅពេលក្រោយ៕

## ឯកសារយោង


Bakker, H.T. 2019. ‘Origin and Spread of the Pāśupata Movement about Heracles, Lakulīśa and Symbols of Masuclinity’, in *Where Art and Text Meet, Studies in the Cultural History of India*, available online in https://www.jstor.org/stable/10.1163/j.ctv2gjwvf9.32

Ben, W. 2018. *Seeing the ‘Foreigner’ In the Art of Early Southeast Asia c. 1000 BCE – c. 900 CE*, Thesis submitted for the degree of PhD, SOAS University of London.

Bhandarkar, R.G. 1931-32. (ed. and trans). ‘Mathura Pillar Inscription of Chanragupta II, G.E. 61’, *Epigraphia Indica,* XXI, pp.1-9.

Bhattacharya, K. 1955. ‘La secte des Pāçupata dans l’ancient Cambodge’ *Journal Asiatique*, 243/4: 480-487.

Chakraboti, H. 1969. *Pāśupata Sūlram ; Samuel Beal, Buddhist Records of the Western World*, reprint ed. (Delhi: Oriental Books Reprint Corp., 1969), under “Pāśupata” and in Book II, pp. 310-11.

Chemburkur, S. 2022. ‘Dancers, Musicians, Ascetics, and Priests: Performance-Based Saiva Worship and its Development in the Temple Cults of Angkor’, in Andrea Acri and

Peter Sharrock (eds.), *The Creative South, Buddhist and Hindu Art in Mediaeval Maritime Asia*, pp.192-221, Volume 1.

Cecil, E.A. 2020. 'Seeking the 'Lord with a Club': Encountering Lakulīśa in the Pāśupata Landscape', in *Mapping the Pāśupata Landscape*, available online in https://www.jstor.org/stable/10.1163/j.ctv2gwz5m.10

Chimanlal, D.D. (eds.) 1966. *Gaṇakārikā of Āchārya Bhāsarvajňa*, Oriental Institute, Baroda.

Chemburkur, S. and Kapoor, S. 2018. 'Pāśupata Sect in Ancient Cambodia and Champa: Art Historical Evidence', in Vô Vân Thâng and Peter D. Sarrock (eds.), *Masterpiece of the Da Nang Museum of Cham Sculpture*, pp. 45-57, Bangkok: River Books.

Choubey, M.C. 1997. *Lakulīsa in Indian Art and Culture*, Delhi: Sharada Publishing House.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION



រូបលេខ១៖ ចម្លាក់អ្នករាំ និងអ្នកភ្លេងលើផ្តែរខាងលិចប្រាសាទយាយព័ន្ធ តួប៉ម S1



រូបលេខ២៖ ចម្លាក់អ្នករាំ និងអ្នកភ្លេងលើផ្តែរមកពីថាឡាបរិវ៉ាត់



រូបលេខ៣៖ ចម្លាក់អ្នករាំ និងអ្នកភ្លេងលើផ្តែរមកពីវត្តមហារ (វត្តអង្គខ្នារ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី